# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0053**

## សម្ភាសន៍ជាមួយឈ្មោះ ជា ពៅ ភេទស្រី អាយុ៥៣ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហមៈ «នារីកាត់ដេរ»
## មុខងារបច្ចុប្បន្នៈ «កសិករ»
## ស្រុកកំណើតនៅភូមិក្រឡង់ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ
## រស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៧ខែតុលា ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ សោម ប៊ុនថន
## ០០:៣៦:៥៨
## ២១ទំព័រ

ប៊ុនថនៈ ចឹងជំបូងសុំស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

ពៅៈ ខ្ញុំឈ្មោះជា ពៅ ។

ប៊ុនថនៈ មីងអាយុប៉ុន្មានឆ្នាំហើយ?

ពៅៈ ឥឡូវខ្ញុំអាយុ៥៣ហើយ ។

ប៊ុនថនៈ មីងនៅក្មេង?

ពៅៈ សើច...ខ្ញុំ៥៣ហើយ ។

ប៊ុនថនៈ មីងនៅស្រុកណាដែរ?

ពៅៈ ខ្ញុំនៅស្រុកកំពង់ស្ពឺ ស្រុកកំណើត ។

ប៊ុនថនៈ បាទ!ភូមិឃុំអីដែលមីង?

ពៅៈ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។

ប៊ុនថនៈ ភូមិអីវិញ?

ពៅៈ ភូមិក្រឡង់ ។

ប៊ុនថនៈ មីងមានបងប្អូនប៉ុន្មាននាក់?

ពៅៈ បងប្អូន៦នាក់ ។

ប៊ុនថនៈ មីងកូនទីប៉ុន្មាន?

ពៅៈ ខ្ញុំកូនទីបួនហើយ ។

ប៊ុនថនៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ពៅៈ ប្រុសពីរស្រីបួន ។

ប៊ុនថនៈ ចឹងឪពុកម្ដាយអ្នកមីងគាត់នៅរស់ទេ?

ពៅៈ ស្លាប់អស់ហើយ ។

ប៊ុនថនៈ គាត់ស្លាប់យូរនៅ?

ពៅៈ ស្លាប់យូរហើយតាំងពីខ្ញុំនៅតូចៗនោះ បើម៉ែស្លាប់ឆ្នាំ៧៩ ។

ប៊ុនថនៈ គាត់ស្លាប់ដោយសារអីដែរអ្នកមីង?

ពៅៈ ឈឺអីដឹងបើខ្ញុំមិនដឹងលែងរត់ចេញមកបាត់ហើយ សើច...ឈឺចាស់ហ្នឹងទំនង ។

ប៊ុនថនៈ ចឹងមីងបែកចេញពីផ្ទះនៅឆ្នាំណា?

ពៅៈ ឆ្នាំ៧៦ ។

ប៊ុនថនៈ ចឹងមីងនៅក្នុងភូមិមានបានរៀនអីទេ កាលនៅតូចៗហ្នឹង?

ពៅៈ អត់បានរៀនទេ ។

ប៊ុនថនៈ ចឹងមីងនៅជាមួយឪពុកលម្ដាយរហូត?

ពៅៈ បែក៧៦ហ្នឹងមកនៅកងចល័ត ។

ប៊ុនថនៈ កងចល័តនៅណាវិញមីង?

ពៅៈ កាលហ្នឹងកងចល័តនៅស្រុកយើង នៅស្រុកនៅឃុំហ្នឹង ។

ប៊ុនថនៈ ឃុំណា?

ពៅៈ ឃុំសេដ្ឋហ្នឹង ។

ប៊ុនថនៈ មីងចូលកងចល័តជាមួយក្មេងនៅក្នុងភូមិ?

ពៅៈ នៅក្នុងភូមិ ។

ប៊ុនថនៈ ច្រើនទេ កាលហ្នឹងអ្នកមីង?

ពៅៈ ច្រើន កាលហ្នឹងកងចល័តច្រើនសើច..នៅតាមកង ។

ប៊ុនថនៈ មាននារីមានក្មេងប្រុសៗទេ?

ពៅៈ មានប្រុសមានស្រីហ្នឹងណាស់ ដល់ចេញពីឃុំមក៧៩ហ្នឹងរត់រហូត ។

ប៊ុនថនៈ កងចល័ត?

ពៅៈ កងចល័តយើងនេះអន្លុងរបូរីនេះ ។

ប៊ុនថនៈ អន្លុងរបូរី?

ពៅៈ អន្លុងរបូរីយើងនេះ ។

ប៊ុនថនៈ ចឹងមីងនៅកងចល័តភូមិរហូតអ្នកមីង?

ពៅៈ នៅកងចល័តភូមិដល់ហើយគេបញ្ជូនយើងមកកងចល័តតំបន់នេះ នៅខេត្តបាត់ដំបងនេះ ។

ប៊ុនថនៈ បាទ!ឆ្នាំណាគេបញ្ជូនមកបាត់ដំបងនេះ?

ពៅៈ ៧៦មកនៅហ្នឹង៧៧ យើងនៅរហូតដល់៧៩រត់ណាស់ ។

ប៊ុនថនៈ ៧៦ហ្នឹងមីងចេញមកពី?

ពៅៈ ពីស្រុកហើយ ។

ប៊ុនថនៈ ចេញមកច្រើនគ្នាដែលទេអ្នកមីង?

ពៅៈ ចេញមកតាមកងមកច្រើនដែលហ្នឹងណាស់ បែកគ្នានៅតាមកងទៀតចឹងទៅណាស់ គេមិនមែននៅជុំគ្នាអីសើច...។

ប៊ុនថនៈ ចេញមកពីឃុំបសេដ្ឋហ្នឹងច្រើសរើសឬមីងស្ម័គ្រចិត្ត?

ពៅៈ ហ្នឹងគេរើសមក ។

ប៊ុនថនៈ កាលហ្នឹងមានគ្នាប៉ុន្មាននាក់មីង?

ពៅៈ កាលហ្នឹងមកច្រើនដែលហ្នឹងមានគ្នាបួនដបនាក់ដែលហ្នឹង ។

ប៊ុនថនៈ នៅក្នុងឃុំមីងហ្នឹង?

ពៅៈ ចាស ។

ប៊ុនថនៈ មកដល់នៅភូមិឃុំអីដែលអ្នកមីង?

ពៅៈ នៅអន្លង់រវៀហ្នឹងមិនដឹងនៅភូមិឃុំអីៗ ជំនាន់ហ្នឹងភ្លេចអស់ហើយសើច...។

ប៊ុនថនៈ ចាំតែស្រុកអន្លង់រវៀ?

ពៅៈ ចាស ។

ប៊ុនថនៈ មីងនៅហ្នឹងធ្វើអីដែលកាលហ្នឹង?

ពៅៈ កាលហ្នឹងនៅកាត់ដេរ ។

ប៊ុនថនៈ កាត់ដេរ?

ពៅៈ ចាស ។

ប៊ុនថនៈ គេហៅអីវិញកាលហ្នឹង កាត់ដេរហ្នឹងគេមានឈ្មោះគេហៅ?

ពៅៈ កាត់ដេរតំបន់ហ្នឹងភ្លេចបាត់ហើយនេះ មិនដឹងជាកាត់ដេរអីទេ កាលហ្នឹងនៅតំបន់ ។

ប៊ុនថនៈ កាត់ដេរតំបន់?

ពៅៈ ចាស ។

ប៊ុនថនៈ កងមីងមកពីខាងបសេដ្ឋហ្នឹងមកកាត់ដេរទាំងអស់?

ពោះ		អត់ទេ  មកតែឯង  បែកគ្នាអស់ហើយខ្លះគេទៅនៅពេទ្យ  ខ្លះទៅនៅនេះទៅណាស់  គេជ្រើសដាក់តាមកន្លែង ។

ប៊ុនថន៖		បាទ!តំបន់ប៉ុន្មានមីងកាលហ្នឹង  តំបន់ប៉ុន្មានកាលកាត់ដេរ?

ពោះ		មិនដឹងជាតំបន់អីទេកាលហ្នឹង  ភ្លេចបាត់ហើយ ។

ប៊ុនថន៖		បាទ ។

ពោះ		វាមិនបានចាំសើច... ។

ប៊ុនថន៖		កាត់ដេរហ្នឹងមីងធ្វើការអីដែរ?

ពោះ		យើងនៅដេរហ្នឹង  យើងនៅកាត់ដេរហ្នឹងតែម្តង  កាត់ដេរឲ្យតំបន់គេហ្នឹង ។

ប៊ុនថន៖		ដេរអីដែរ?

ពោះ		ដេរខោអាវ ។

ប៊ុនថន៖		មីងពីមុនមក  មីងចេះដេរដែរ?

ពោះ		ពីមុនមកខ្ញុំអត់ចេះដងសើច...រៀនដេរហ្នឹង ។

ប៊ុនថន៖		រៀនដេរយូរទេបានចេះដេរ?

ពោះ		រៀនដេរនៅហ្នឹងយូរដែលហ្នឹងមួយឆ្នាំពីរឆ្នាំដែលហ្នឹង ។

ប៊ុនថន៖		ចឹងពីមុនមកមីង?

ពោះ		អត់ចេះទេ ។

ប៊ុនថន៖		ចឹងមករៀនរយៈពេលប៉ុន្មានបានមីងចេះដេរ?

ពោះ		រៀនយូរដែលហ្នឹង  យើងគ្រាន់តែដេរមានគេអ្នកកាត់  គ្រាន់តែដេរខោអាវរដ្ឋខោអាវរយហ្នឹង ។

ប៊ុនថន៖		ដេរម៉ាស៊ីនឬក៏ដេរ?

ពោះ		ម៉ាស៊ីន ។

ប៊ុនថន៖		ដេរធាក់ជើងឬដេរម៉ូទ័រគេ?

ពោះ		អត់ទេ  ដេរធម្មតា  ជំនាន់ហ្នឹងគ្មានម៉ូទ័រទេសើច... ។

ប៊ុនថន៖		ចឹងនៅកងដេរមានគ្នាច្រើនទេ?

ពោះ		ច្រើន៦០នាក់ ។

ប៊ុនថន៖		មួយថ្ងៃបានប៉ុន្មានទៅ?

ពោះ		មួយថ្ងៃគេកំណត់ដេរបួនកម្ទេ ។

ប៊ុនថន៖		បួនកម្ទេ?

ពៅៈ ចាស ។

ប៊ុនថនៈ ប្អូនកម្ទាំងខោទាំងអាវហ្នឹង?

ពៅៈ ទាំងខោទាំងអាវ ។

ប៊ុនថនៈ មីងដេរទាន់ដែរ?

ពៅៈ ដេរបានតើ អាវយើងអត់ម៉ូតអាវធម្មតា អាវកខុបដៃបំពង់ ខ្លះដៃជីបទៅ ។

ប៊ុនថនៈ ដេរហ្នឹងមានប្រធានក្រុមគេដែរ?

ពៅៈ មានប្រធានក្រុម ។

ប៊ុនថនៈ ប្រធានក្រុមមកពីនេះដែរ?

ពៅៈ ប្រធានក្រុមនៅស្រុកគេនេះ ស្រុកអន្លង់វែងហ្នឹង ។

ប៊ុនថនៈ មួយក្រុមមានគ្នាប៉ុន្មាននាក់?

ពៅៈ មួយក្រុមមានគ្នា១០នាក់ ។

ប៊ុនថនៈ ចឹង៦០នាក់មាន៦ក្រុម?

ពៅៈ ៦ក្រុម មួយកងធំគេសើច... ។

ប៊ុនថនៈ មានប្រធានកងគេ?

ពៅៈ មានប្រធានកងគេ មានប្រធានក្រុម ។

ប៊ុនថនៈ ចឹងក្រៅពីដេរមីងធ្វើអីទៀតមីង?

ពៅៈ អត់មានធ្វើអីទេ នៅតែដេរតែម្តងនៅហ្នឹង ដល់ម៉ោងយើងដេរ ។

ប៊ុនថនៈ ដេរប៉ុន្មានម៉ោងឈប់?

ពៅៈ ដេរដល់ម៉ោង១២សម្រាក ម៉ោង១ចុះទៀត ធ្វើការគ្មានម៉ោងសម្រាក ។

ប៊ុនថនៈ ចឹងមីងនៅហ្នឹងរហូតអត់មានដែលចេញទៅក្រៅទេ?

ពៅៈ អត់មានទៅណាទេ ។

ប៊ុនថនៈ ចឹងកាលបែកចេញពីផ្ទះមកកាត់ដេរតំបន់ឪពុកម្តាយមានដឹងទេ?

ពៅៈ ចេញពីផ្ទះដឹង ។

ប៊ុនថនៈ ដឹង?

ពៅៈ ចាស ។

ប៊ុនថនៈ ចឹងពេលដែលមីងមកកន្លែងដេរហ្នឹងមីងមានដែលទៅផ្ទះលេងទេ?

ពៅៈ អត់ អត់ដែលទៅទេ រត់ដល់យើងរត់បែកគ្នារហូត ។

ប៊ុនថនៈ ដល់ពេលរត់មីងនៅកន្លែងកាត់ដេរហ្នឹងដល់ឆ្នាំណា មានដូរទៅកន្លែងផ្សេងទៀតទេ?

ពោះ: ឆ្នាំ៧៧ដូរ ។

ប៊ុនថន: ដូរទៅណាវិញ?

ពោះ: ដូរមកភ្នំពេញវិញសើច..។

ប៊ុនថន: ចឹងដូរទៅភ្នំពេញវិញ?

ពោះ: ដូរទៅភ្នំពេញវិញ ។

ប៊ុនថន: ជ្រើសរើសទៅឬមីងសុំទៅ?

ពោះ: ហ្នឹងគេបញ្ជូនទៅគេជ្រើសរើសទៅវិញ ។

ប៊ុនថន: ទៅនៅភ្នំពេញទៅនៅកន្លែងណាវិញ?

ពោះ: ទៅនៅកន្លែងស្អីទេ ទៅនៅកន្លែងតាខ្មៅ មកដល់ហ្នឹងគេដកមកកន្លែងលុតដុំវិញហើយ ។

ប៊ុនថន: គេហៅអីវិញនៅតាខ្មៅហ្នឹង?

ពោះ: គេហៅកន្លែង«ក»ប៉ុន្មានទេ តាខ្មៅហ្នឹង ខ្ញុំភ្លេចបាត់ទៀតហើយហ្នឹង យូរហើយនៅហ្នឹងទៅរហូតដល់រត់យួន៧៩ហ្នឹងឯង ។

ប៊ុនថន: នៅហ្នឹងមីងធ្វើអីវិញ?

ពោះ: នៅហ្នឹងមកធ្វើដាំដំណាំអីវិញហើយ ។

ប៊ុនថន: ចឹងនៅហ្នឹងមានក្រសួងអីទេ?

ពោះ: មានក្រសួងគេតែភ្លេចឈ្មោះទៀតទៅណាស់សើច...។

ប៊ុនថន: ទៅច្រើនទេ ដកពីកន្លែងកាត់ដេរទៅ?

ពោះ: ទៅប៉ុន្មាន៥ ទៅ៦នាក់ដែលហ្នឹងណាស់ ។

ប៊ុនថន: ទៅនៅជាមួយគ្នាឬបែកគ្នា?

ពោះ: ទៅនៅជាមួយគ្នា ។

ប៊ុនថន: ដាំបន្លែ?

ពោះ: ដាំបន្លែដាំអី ។

ប៊ុនថន: កាលហ្នឹងនៅខាងណាតាខ្មៅមីង?

ពោះ: កាលហ្នឹងដឹងខាងណាតាខ្មៅទេ ហួសផ្សារតាខ្មៅទៅ មកជិតណាទេ ភ្លេចអស់ហើយភ្នំពេញមិនសូវស្គាល់អស់ក្រឡុកក្រលៀតសើច...។

ប៊ុនថន: មីងមិនដែលទៅទេ ទើបទៅពេលបញ្ជូនទៅហ្នឹង?

ពោះ: ហ្នឹងហើយ មិនដែលទៅទេ ។

ប៊ុនថន: មានប្តែកទេមីង ពេលទៅ?

ពៅៈ កាលហ្នឹងដូចថាវាមិនប្លែកអី មិនសូវមានមនុស្សច្រើនផងស្ងាត់ទ្រឹងដែរសើច...។

ប៊ុនថនៈ ទៅជិះឡានទៅមីង ពីនេះទៅ?

ពៅៈ ជិះឡាន ។

ប៊ុនថនៈ ប៉ុន្មានថ្ងៃបានដល់?

ពៅៈ មួយថ្ងៃហ្នឹងនៅពេលយប់ដល់ យប់បានដល់ ។

ប៊ុនថនៈ មីងទៅគ្នាច្រើនទេ នៅកន្លែងដាំបន្លែហ្នឹង?

ពៅៈ គ្នាច្រើន ។

ប៊ុនថនៈ ទាំងអស់គ្នាប៉ុន្មាននាក់?

ពៅៈ គ្នាច្រើនដែលគ្នា៥០ទៅ៦០នាក់ដែលហ្នឹង កងគេដែលសុទ្ធតែកងៗគេ ។

ប៊ុនថនៈ ក្រៅពីដាំបន្លែមីងមានធ្វើការងារអីផ្សេងទៀតទេមីង?

ពៅៈ អត់មានធ្វើការអីទេ ។

ប៊ុនថនៈ ដាំអីខ្លះមីងនៅហ្នឹង?

ពៅៈ ដាំស្ពៃដាំបន្លែគ្រប់មុខហ្នឹងសើច...។

ប៊ុនថនៈ ដាំបានច្រើនទេ?

ពៅៈ ដាំច្រើន ។

ប៊ុនថនៈ ដាំហូបខ្លួនឯងឬយ៉ាងម៉េច?

ពៅៈ ដាំហូបខ្លួនឯងផងគេបញ្ជូនទៅតាមកងផង ។

ប៊ុនថនៈ គេបញ្ជូនទៅកងណាខ្លះមីង?

ពៅៈ កងផ្សេងៗហ្នឹងណាស់ តាមអង្គភាពផ្សេងៗ ។

ប៊ុនថនៈ ចឹងមានអ្នកដាំផ្សេងមានអ្នកបញ្ជូនទៅផ្សេង?

ពៅៈ ចាស ។

ប៊ុនថនៈ ចឹងមីងមានបានដើរលេងទៅភ្នំពេញអីទេ?

ពៅៈ អត់ទេ មិនដែលបានដើរលេងទេ សើច...។

ប៊ុនថនៈ ដើរទៅមុខវាំងដើរទៅអី?

ពៅៈ អត់ទេ សើច...។

ប៊ុនថនៈ វត្តភ្នំ?

ពៅៈ ជំនាន់ហ្នឹងមានពីណាឲ្យដើរលេង រហេករហូតនោះ ។

ប៊ុនថនៈ បាទ!ចឹងមីងអត់មានបានដើរទស្សនៈកិច្ចនៅណាទេមីង?

ពៅៈ អត់ អត់ដែលបានដើរ ។

ប៊ុនថនៈ នៅកងមីងមិញមានប្រធានគ្រប់គ្រងទេមីង?

ពៅៈ មាន សុទ្ធតែមានហើយ ។

ប៊ុនថនៈ បាទ!ហ្នឹងគេហៅកន្លែងអីមីង?

ពៅៈ ភ្លេចអស់ហើយហ្នឹង យើងរត់ចេះមកវាមិនសូវចាប់អារម្មណ៍ទៀតភ្លេចអស់ហើយ ។

ប៊ុនថនៈ នៅមន្ទីរគេហៅមន្ទីរ?

ពៅៈ ហ្នឹងហើយគេហៅមន្ទីរស្អីទេភ្លេចអស់ហើយ ដឹងតែកន្លែងនៅភ្លេចឈ្មោះមន្ទីរហ្នឹងទៀត ។

ប៊ុនថនៈ បាទ!តែនៅក្រោមក្រសួងអីវិញមីង?

ពៅៈ ហ្នឹងហើយក្រសួង ក្រសួងស្អីគេភ្លេចអស់ហើយណាស់ ។

ប៊ុនថនៈ នៅហ្នឹងរហូតឬមានផ្លូរទៅធ្វើការកន្លែងផ្សេងទៀត?

ពៅៈ អត់ទេ នៅហ្នឹងរហូតដល់យើងរត់យួនឆ្នាំ៧៩ហ្នឹង ។

ប៊ុនថនៈ រត់៧៩ មីងរត់ទៅណាវិញ?

ពៅៈ រត់មកយើងព្រំដែនហ្នឹង ចេញពីហ្នឹងរត់មកហ្នឹង ។

ប៊ុនថនៈ មីងរត់តាមផ្លូវណាវិញមីង?

ពៅៈ តាមផ្លូវណាណីសើច..ឆ្ងាយណាស់ចេះតែមកៗតាមគ្នារហូតមក ។

ប៊ុនថនៈ រត់តាមបាត់ដំបងនេះឬរត់តាមផ្លូវណាវិញ?

ពៅៈ រត់តាមបាត់ដំបងហ្នឹងឯងតាមមើល តាមបាត់ដំបងពោធិសាត់ហ្នឹងឯង ។

ប៊ុនថនៈ តាមបាត់ដំបង?

ពៅៈ ចាស!តាមហ្នឹងឯង ។

ប៊ុនថនៈ មកទាំងអស់កន្លែងកងមីងហ្នឹង?

ពៅៈ មកទាំងអស់ ចេញមកទាំងអស់គ្នា ។

ប៊ុនថនៈ មីងរត់ដំបូង មីងរត់ទៅណាវិញ គោលដៅ?

ពៅៈ គោលដៅរត់ចេញពីហ្នឹងមក រត់វៀងមកនេះវិញ មកព្រំដែនហ្នឹង ។

ប៊ុនថនៈ តែមកតាមគ្នាឬមួយមានអ្នកដឹកនាំអីដែរ?

ពៅៈ កាលហ្នឹងមានពីណាដឹកនាំ ផ្អើលមករត់តាមគ្នាមក ។

ប៊ុនថនៈ បាទ ។

ពៅៈ ហ្នឹងឯង រត់ព្រូចុះព្រូឡើងតាមតែគ្នា ។

ប៊ុនថនៈ ចឹងកងមីងពីណាដឹកនាំទៅ មកទាំងមេដឹកនាំ?

ពោះ	មកទាំងអស់ ដល់ហើយបែកគ្នាមិនដឹងពីណាមកណាទៅណា រត់យករាងតែខ្លួនមក ។

ប៊ុនថន៖	បាទ ។

ពោះ	ហ្នឹងឯងបែកគ្នាអស់ ។

ប៊ុនថន៖	និយាយមកគ្នាច្រើនទេ តាមផ្លូវ?

ពោះ	មកច្រើន តាមផ្លូវមកច្រើនណាស់ ពពាក់ពពូនគ្នាហ្នឹង មនុស្សរាប់រយរាប់ពាន់នោះ ។

ប៊ុនថន៖	រាប់ពាន់នាក់?

ពោះ	ហ្នឹងរត់ចេញមកគ្រប់តែកន្លែង ។

ប៊ុនថន៖	ច្រើនចឹងបានអីហូបទៅមីង?

ពោះ	តាមផ្លូវខ្លះបានហូបទៅខ្លះអត់ទៅ ដាច់ទាំងបាយដាច់ទាំងទឹកទៀតនោះសើច... ។

ប៊ុនថន៖	ចឹងមានអ្នកឈឺមានអ្នកអីដែលមីង?

ពោះ	មាន មានឈឺស្លាប់អត់បាយអត់ទឹក ខ្លះគ្នាដើរមិនរួចទៅផាប់ទៅមានពីណាយកពីណាមានពេទ្យមានអីណាជំនាន់ហ្នឹង ។

ប៊ុនថន៖	មានស្លាប់ច្រើនគ្នាទេមីង?

ពោះ	ស្លាប់ច្រើនដែលហ្នឹង តាមមើលទៅមានពេទ្យណាមានពីណាសែង បើអស់កំលាំងរៀងខ្លួនទុកតែចោលគ្នា តាមអាហ្នឹងទៅ ។

ប៊ុនថន៖	បាទ! ចឹងមីងមកដំបូងប៉ុន្មានថ្ងៃបានមកដល់?

ពោះ	យូរណាស់មិនដឹងជាប៉ុន្មានថ្ងៃទេអូន រត់ហ្នឹងរត់យូរណាស់មិនដឹងជាប៉ុន្មានថ្ងៃប៉ុន្មានខែហ្នឹងដល់ព្រំដែននេះទេ ។

ប៊ុនថន៖	មីងមកដល់ហ្នឹងដូចឆ្នាំប៉ុន្មានហើយមីង?

ពោះ	មិនដឹងជាឆ្នាំប៉ុន្មានទេ តាំងពីខ្ញុំនៅក្មេងៗដែលកាលរត់៧៩ហ្នឹងដឹងឆ្នាំប៉ុន្មានដល់ព្រំដែនទេនេះ ។

ប៊ុនថន៖	កាលហ្នឹងមីងអាយុប៉ុន្មានហើយ?

ពោះ	កាលហ្នឹងអាយុប្រហែលជា២០ជាងហ្នឹងហើយ ។

ប៊ុនថន៖	រត់មកម៉ាឡៃនេះតែមីង?

ពោះ	ចាស ។

ប៊ុនថន៖	ម៉ាឡៃមីងនៅម្តុំណាវិញទៅទៅ កាលមកដល់ដំបូង?

ពោះ	មកដល់ដំបូងមកដល់ព្រំដែន អូរខាងនេះឯង ។

ប៊ុនថន៖	អូរព្រំដែននេះមីង?

ពោះ: ចាស ។

ប៊ុនថន: មកដល់ដំបូងមីងឃើញតំបន់ម៉ាឡៃហ្នឹងយ៉ាងម៉េចដែរ?

ពោះ: ម៉ាឡៃមកដល់ដំបូងសុទ្ធព្រៃហ្នឹង គ្មានផ្ទះឯណា សុទ្ធតែព្រៃមិនហ្នឹង មានមនុស្សមានម្នាអី សុទ្ធតែព្រៃហ្នឹង ។

ប៊ុនថន: ព្រៃយ៉ាងម៉េចមីងព្រៃហ្នឹង?

ពោះ: ព្រៃឈើធំៗតែម្តងទៅណាស់ ។

ប៊ុនថន: ចឹងមានផ្លូវអីដែលមីង?

ពោះ: កាលមកដល់ដំបូងអត់មានផ្លូវទេ មានតែផ្លូវយើងធ្វើឆ្ការរាវនៅហ្នឹងណាស់ ។

ប៊ុនថន: ចឹងមីងថាមានគ្រាប់មីន កាលមកដល់ដំបូងមានទេ?

ពោះ: មានតើ មានខ្សែទ្រៀមយួនអីដែលហ្នឹងណាស់ តែពួកយើងគេដោះគេអីទៅ គេធ្វើកន្លែងនៅទៅ ។

ប៊ុនថន: បាទ! តែកាលមីងមកដល់ដំបូងគេមានគ្រាប់មីនដែរ?

ពោះ: អត់ទាន់មានទេ មកដំបូងមិនទាន់មានមីនទេ ។

ប៊ុនថន: បាទ ។

ពោះ: ដល់មកហ្នឹងយួនវៃមួយសារទៀត មកនៅម៉ាឡៃវិញទៀតបានមានមីន រត់មួយសារទៀត ទៅដល់ដីថៃនោះ ។

ប៊ុនថន: ខាងណាជាអ្នកដាក់មីន មីង?

ពោះ: យួនដឹង មីនយួនហើយបើយើងធ្វើសង្គ្រាមជាមួយយួននោះសើច...មានតែយួន ។

ប៊ុនថន: មីងមកដល់ដំបូងហូបចុកស្នាក់នៅអីយ៉ាងម៉េចដែរ សុទ្ធព្រៃហ្នឹង?

ពោះ: មកដល់ដំបូងយ៉ាប់ដែលហ្នឹង យើងនៅឆ្ការអីត្រឹមត្រូវមានកាកក្របាទគេផ្តល់អង្ករអីឲ្យបាន ស្រួល ។

ប៊ុនថន: និយាយរស់នៅមីងរស់នៅយ៉ាងម៉េចដែរ ព្រោះសុទ្ធតែព្រៃចឹង?

ពោះ: រស់នៅមានអីយើងធ្លាប់ហើយ យើងធ្លាប់នៅព្រៃហើយសើច...យើងរត់មកនេះយើងនៅយូរឆ្នាំហើយ មានអីពិបាក កាលហ្នឹងយើងនៅខ្លួនមួយមានកូនមានចៅអី ។

ប៊ុនថន: ម្នាក់ឯងមីង?

ពោះ: ចាស!មិនទាន់មានកូនចៅមានប្តីមានប្រពន្ធអីណា ។

ប៊ុនថន: ចឹងមានអ្នកស្គាល់មកជាមួយមីងទេ?

ពោះ: កាលរត់មកស្គាល់គ្នានៅជុំគ្នាដដែលហ្នឹង នៅជិតៗគ្នា ។

ប៊ុនថន៖ កាលហ្នឹងមីងនៅម្ខាងចូលដល់ដីថៃឬមួយមីងនៅខាងខ្មែរទេ?

ពោះ៖ នៅខាងខ្មែរ ។

ប៊ុនថន៖ ចឹងនៅហ្នឹងមានប៉ះគ្នាទេ កំលាំងតស៊ូជាមួយកំលាំងខាងក្នុងមានវ៉ៃគ្នាមានអីទេ?

ពោះ៖ នៅតាមព្រំដែនអត់មានប៉ះគ្នាទេ ទ័ពនៅខា

ងមុខបានប៉ះគ្នា យើងនៅនេះអត់ទេ បើមាន ការគេដកទៅបាត់ទៀតហើយ អត់មានឲ្យប៉ះគ្នាទេ

អ្នកមានកូនមានចៅអីទេ ។

ប៊ុនថន៖ បាទ ។

ពោះ៖ គេការពារនៅខាងមុខ ។

ប៊ុនថន៖ ចឹងនៅនេះភាគច្រើនជាកងទ័ពឬជាប្រជាជនធម្មតា?

ពោះ៖ នៅនេះសុទ្ធតែកងទ័ពទាំងអស់ហ្នឹង ប្រជាជនអ្នកចាស់ហ្នឹងមិនសូវមានទេ ។

ប៊ុនថន៖ អ្នកមីងខាងនេះដែរ?

ពោះ៖ ចាស!យើងអ្នករត់ចេញពីស្រុកមកទាំងអស់គ្នាសុទ្ធនៅកង នៅមន្ទីរដូចគ្នាហ្នឹងណាស់ ។

ប៊ុនថន៖ ចឹងមីងនៅនេះ នៅកងអីវិញមីង?

ពោះ៖ ឥឡូវនេះនៅភូមិ ។

ប៊ុនថន៖ អត់ទេ និយាយថាកាលពីមុន កាលមកដល់ដំបូង?

ពោះ៖ មកដល់ដំបូងមកពីនោះវាបែកកងអស់ហើយ នៅតាមឯកជនរៀងខ្លួន ។

ប៊ុនថន៖ ឯកជន?

ពោះ៖ ហ្នឹងហើយរកកន្លែងនៅរៀងខ្លួន ។

ប៊ុនថន៖ ចឹងរបបអីគេផ្តល់ឲ្យប្រជាជននិងកងទ័ពដែរ?

ពោះ៖ ចាស!ទាំងកងទ័ពរបបបើកឲ្យហូប ។

ប៊ុនថន៖ ចឹងនិយាយថាហូបគ្រប់ទេ?

ពោះ៖ ហូបគ្រប់តើ ជំនាន់ហ្នឹងអត់មានអត់ទេ គេបើកឲ្យហូបគ្រប់គ្រាន់ អង្ករអីបើកឲ្យហូបគ្រប់គ្រាន់ តែយើងអត់បានលុយចាយជំនាន់ហ្នឹង ជំនាន់ហ្នឹងអត់មានលុយបើកអង្ករឲ្យហូបគ្រប់គ្រាន់ហ្នឹង ។

ប៊ុនថន៖ បាទ ។

ពោះ៖ ស្លៀកពាក់គ្រប់គ្រាន់ ។

ប៊ុនថន៖ ចឹងមានប៉ះគ្នាដែលជាមួយកំលាំងខាងក្នុងមីង?

ពោះ៖ នៅយើងនេះដូចអត់ដែលមានប៉ះគ្នាទេ ខ្មាចនៅមុខៗដឹងបើនៅនេះតាមជួរព្រំដែនអត់ទេ ។

ប៊ុនថន៖ ចឹងមីងនៅតែខាងខ្មែរមីងមានទៅដល់ថៃទេមីង?

ពៅ៖ ទៅដល់តើ ទៅដល់ថៃរត់ទៅដល់ថៃ។

ប៊ុនថន៖ រត់ពេលណាវិញមីង?

ពៅ៖ ពួហ្នឹងទៅគេដឹកទៅ ទៅនៅថៃ។

ប៊ុនថន៖ គេដឹកទៅថៃ?

ពៅ៖ ចាស។

ប៊ុនថន៖ កាលហ្នឹងឆ្នាំណា កាលទៅ?

ពៅ៖ កាលយើងទៅថៃឆ្នាំប៉ុន្មានអី ភ្លេចហើយអានេះមិនទាន់កើតផងសើច...មិនដឹងជាឆ្នាំប៉ុន្មានទេ យើងយួនបុកនេះទៅថៃបានមួយឆ្នាំដែលហ្នឹងបានមក។

ប៊ុនថន៖ នៅបានប៉ុន្មានឆ្នាំមីង?

ពៅ៖ មួយឆ្នាំដឹង មួយឆ្នាំជាង ទៅនៅដីថៃកើតបានកូនមួយហើយ កូនពីរហើយហ្នឹងឯង។

ប៊ុនថន៖ បានពីរហើយបានរត់ទៅថៃ?

ពៅ៖ បានកើតនៅស្រុកថៃពីរ នេះអានេះមួយហើយអាបងនោះ បានប្រពន្ធនោះមួយ។

ប៊ុនថន៖ ចឹងនៅយូរដែរ?

ពៅ៖ នៅយូរកើតបានពីរហើយហ្នឹងបានមក បានមកដីខ្មែរយើងវិញហ្នឹង បានមកនៅយើងនេះវិញដល់សព្វថ្ងៃនេះ។

ប៊ុនថន៖ ចឹងមីងការឆ្នាំណាមីង?

ពៅ៖ ការឆ្នាំប៉ុន្មាន កាលនៅខ្លាំងរាប់ ៨៤ចេះឯង ៨៤។

ប៊ុនថន៖ ៨៤?

ពៅ៖ ចាស។

ប៊ុនថន៖ ចឹងគ្រួសារមីងធ្វើនេះ?

ពៅ៖ ធ្វើចំការ។

ប៊ុនថន៖ ធ្វើចំការដែរ?

ពៅ៖ ចាស។

ប៊ុនថន៖ កាលហ្នឹងការយ៉ាងម៉េចទៅមីង?

ពៅ៖ សើច..ការកាលហ្នឹងចាប់ដៃគ្នាសើច...។

ប៊ុនថន៖ ច្រើនគូរទេអ្នកមីង?

ពៅ៖ កាលហ្នឹងមិនសូវច្រើនគូរទេ យើងនៅនេះហើយពីរគូរបីគូរអីហ្នឹង។

ប៊ុនថន: តែចង់សួរអ្នកមីងរៀបរាប់ពេលការ ការរបៀបយ៉ាងម៉េច មីងមានស្គាល់គ្នាពីមុនមកទេអ្នកមីង?

ពោ: ស្គាល់គ្នាតើ បើយើងនៅកន្លែងជិតគ្នាសើច.. នៅរត់មកជិតគ្នាជុំគ្នាហ្នឹង ។

ប៊ុនថន: តែពីមុនមកមានទំនាក់ទំនងគ្នាស្គាល់គ្នានិយាយជាមួយគ្នាទេ?

ពោ: អត់ទេ ។

ប៊ុនថន: ចឹងយ៉ាងម៉េច បានៗការទៅមីង?

ពោ: អាហ្នឹងនេះយើងត្រូវគ្នាការទៅ ប្រាប់មេប្រាប់កងទៅ គេការឲ្យទៅសើច... ។

ប៊ុនថន: ការទៅមានពិធីជុបលៀងអីដែរមីង?

ពោ: ទេ អត់មានជុបលៀងអីទេ ។

ប៊ុនថន: ចឹងមានហៅភ្ញៀវអីទេ?

ពោ: អត់មានទេ ។

ប៊ុនថន: ការហ្នឹងការរបៀបម៉េចនៅអង្គភាពតែម្តងឬយ៉ាងម៉េច?

ពោ: ហ្នឹងហើយ នៅអង្គភាពគ្រាន់តែមេអីដឹងញុំចឹងទៅ ។

ប៊ុនថន: មីងនៅកងអីវិញ?

ពោ: យើងនៅនេះខ្វាងរាប់ហ្នឹងហើយណាស់ យើងនៅខ្មែរក្រហមនេះហើយហ្នឹង ។

ប៊ុនថន: តែមីងនៅកងអីវិញ កាលហ្នឹងបានស្គាល់ពូ ពូជាទាហាន?

ពោ: ចាស ។

ប៊ុនថន: មីងនៅខាងអីវិញទៅ?

ពោ: នៅដឹកជញ្ជូន ។

ប៊ុនថន: ដឹកជញ្ជូន?

ពោ: ចាស ។

ប៊ុនថន: ហើយស្គាល់គ្នា?

ពោ: ស្គាល់គ្នា ។

ប៊ុនថន: រួចស្នើរទៅលើ?

ពោ: ចាស ។

ប៊ុនថន: កាលឆ្នាំណា?

ពោ: ឆ្នាំ៨៤ ។

ប៊ុនថន: ចឹងការបានប៉ុន្មានបានមីងទៅថៃ?

ពៅៈ ការហើយរត់៨៩រត់ ៨៩ យើងរត់ពីហ្នឹងទៅថៃ ។

ប៊ុនថនៈ ចូលរត់ដល់ពេលណា?

ពៅៈ ចូលរត់ដល់មានកូនពីរបានចេញមកវិញ ។

ប៊ុនថនៈ កាលហ្នឹងនៅខ្វាងសាប់ហ្នឹងពីនេះទៅប៉ុន្មានគីឡូកាលហ្នឹង?

ពៅៈ កាលហ្នឹងមិនជាប៉ុន្មានគីឡូទេ ដើរទៅមកៗដែលហ្នឹងមានអីជិះ ។

ប៊ុនថនៈ ខ្វាងសាប់ហ្នឹងនៅភូមិអីវិញ?

ពៅៈ ខ្វាងសាប់នៅខ្វាងសាប់តែម្ដង ។

ប៊ុនថនៈ តែគេហៅឃុំអីវិញ?

ពៅៈ ឥឡូវមិនដឹងគេហៅឃុំអីខ្វាងសាប់ហ្នឹង ទួលពន្រ កាលមុនវាអត់មានឃុំអីទេ ហៅថាខ្វាងសាប់ៗតែម្ដង កាលហ្នឹងមានទាន់ចែកឃុំភូមិអីដូចឥឡូវហ្នឹង ទើបតែចែកឥឡូវនេះ ។

ប៊ុនថនៈ ចឹងម៉ាឡៃនេះគេហៅម៉ាឡៃតាំងពីពេលណាមក?

ពៅៈ ម៉ាឡៃទើបតែហៅហ្នឹងដែលហ្នឹង ទើបតែមានស្រុកមានឃុំអីដាក់ ។

ប៊ុនថនៈ មុនគេហៅ?

ពៅៈ មុនគេមានហៅម៉ាឡៃអីណាគេហៅភូមិដូង ។

ប៊ុនថនៈ គេហៅភូមិដូង?

ពៅៈ ហ្នឹងហើយ កាលគេវៃគ្នានៅសង្គ្រាមគេហៅភូមិដូង ម៉ាឡៃទើបមានស្រុកមានភូមិចែកនេះ សើច... ។

ប៊ុនថនៈ ចឹងពៃក្រោយទេ?

ពៅៈ ក្រោយទេ ។

ប៊ុនថនៈ ភូមិដូងមុនគេ?

ពៅៈ មុនគេ ។

ប៊ុនថនៈ មីងនៅខ្វាងសាប់ហ្នឹងបានយូរដែលមីង?

ពៅៈ នៅខ្វាងសាប់យូរដែរ ។

ប៊ុនថនៈ តាំងពីមីងមកដល់ដំបូង?

ពៅៈ ចាស ។

ប៊ុនថនៈ មីងមកដល់ព្រំដែនរយៈពេលប៉ុន្មានបានទៅនៅខ្វាងសាប់?

ពៅៈ មិនដឹងជាបានប៉ុន្មានទេ យើងដើរទៅដើរមក វាពិបាកចំណាំដែរ ម្ដងទៅម្ដងដឹកមកចឹងទៅ មានសភាពការណ៍ចឹងគេដឹកទៅ អត់ធូរស្រួលទៅគេដឹកមកវិញទៅ វាមិនបានចាំ ។

ប៊ុនថន៖	មីងកាលទៅថៃហ្នឹងមីងធ្វើអីវិញ?

ពៅ៖	ទៅថៃមានធ្វើអីគេដាក់នៅអគ្គភាពម៉ាដុំ ខ្មែរយើងនៅម៉ាកាដុបចឹងទៅ មានផ្ទះមានសំបែងនៅថៃហ្នឹង ។

ប៊ុនថន៖	គេហៅអីវិញ?

ពៅ៖	ទដីងភូមិអីទេ ថៃនេះ គេហៅថាជំរំ៨៥ ។

ប៊ុនថន៖	កាលនៅហ្នឹងមានមនុស្សច្រើនទេមីង?

ពៅ៖	ច្រើន មានមនុស្សច្រើនណាស់ខ្មែរយើងទាំងអស់ហ្នឹង ជួរព្រំដែនហ្នឹងនៅហ្នឹង ស្រុកថៃដឹងគេហៅស្រុកអី ។

ប៊ុនថន៖	គេហៅស្រុកអីវិញ?

ពៅ៖	ស្រុកថៃដឹងគេហៅស្រុកអី ។

ប៊ុនថន៖	នៅពីទីនេះប៉ុន្មានគីឡូពីព្រំដែនទៅ?

ពៅ៖	ឆ្ងាយណាស់ជិះឡានមួយថ្ងៃ ជិះឡានមួយថ្ងៃដល់ល្ងាច ។

ប៊ុនថន៖	ប្រហែលជាដីប៉ុន្មានរយគីឡូ?

ពៅ៖	មិនដឹងជាប៉ុន្មានរយគីឡូទេ ឡានធំដឹកមួយថៃដល់ល្ងាចហ្នឹង កាលជំនាន់ហ្នឹងគេដឹកលាក់ដឹកវាងអីទាំងអស់ យូរមួយថ្ងៃដល់ល្ងាច ។

ប៊ុនថន៖	ជំរំ៨៥ហ្នឹងនៅខេត្តអីវិញ?

ពៅ៖	ស្រះកែវមិនមែនណាស់ ប្រហែលស្រះកែវហ្នឹងឯង ។

ប៊ុនថន៖	ចឹងមីងទៅនោះតែមីងទេ ចុះពូ?

ពៅ៖	ប្តីយើងទៅមុខ ។

ប៊ុនថន៖	គាត់ចេញចូលទៅជួបមីងឬគាត់ប្រចាំការនៅនេះ?

ពៅ៖	ចេញចូលតើ ដូចយើងមានរវល់ឈឺស្កាត់អី គេឲ្យទៅសុំច្បាប់គេទៅ គេដឹកឡានទៅថៃបាន បើយើងអត់មានឈឺស្កាត់អីអត់បានទេ នៅមុខរហូត ។

ប៊ុនថន៖	មីងនៅហ្នឹងរហូតដល់ឆ្នាំណាបានមីងមកវិញ?

ពៅ៖	យើងមកឆ្នាំណាទេ មកដីខ្មែរវិញនេះ មិនដឹងជាឆ្នាំណាទេ ភ្លេចអស់ហើយ ។

ប៊ុនថន៖	តែកាលមកហ្នឹងមកទាំងអស់គ្នាតើមីង?

ពៅ៖	មកទាំងអស់គ្នា គេដឹកមកវិញទាំងអស់ ។

ប៊ុនថន៖	ចឹងកាលមកមីងមកនៅផ្ទះនេះសព្វថ្ងៃតែម្តងឬមីងទៅនៅកន្លែងណា?

ពៅ៖	មកដល់នៅនេះសព្វថ្ងៃនេះឯង ។

ប៊ុនថន៖	ផ្ទះហ្នឹង?

ពោះ៖	កាលមុននៅផ្ទះខាងនោះគៀកអូរជិតព្រំដែននោះ ។

ប៊ុនថន៖	មីងដូរមកនេះឆ្នាំណាមីង?

ពោះ៖	ដូរមកនេះឆ្នាំណាទេ មកនៅនេះជិត១០ជាងហើយ នៅនោះបានតែបន្តិចហ្នឹង ។

ប៊ុនថន៖	ផ្ទះនេះមីងទិញគេ គេចែកឲ្យឬចាប់មកនៅខ្លួនឯងមីង?

ពោះ៖	ដីហ្នឹងទិញគេដែរ ។

ប៊ុនថន៖	ចឹងដីចាស់មីងនៅមាត់អូរទេ?

ពោះ៖	នៅខាងនោះទៀតនោះ ។

ប៊ុនថន៖	នៅមាត់អូរហ្នឹងមីងចាប់នៅខ្លួនឯងតែម្ដងឬយ៉ាងម៉េច?

ពោះ៖	អានោះចាប់នៅ យើងឆ្កាព្រៃអីនៅ ។

ប៊ុនថន៖	យ៉ាងម៉េចបានជាមីងដូរនៅនេះវិញ?

ពោះ៖	នៅនោះវាគៀកពេកហើយដីវាចង្អៀត ។

ប៊ុនថន៖	មីងទិញយូរហើយនៅ?

ពោះ៖	ទិញយូរហើយ ។

ប៊ុនថន៖	ចឹងដីមាត់អូរហ្នឹងចោលទៅ?

ពោះ៖	ដីមាត់អូរហ្នឹងនៅជារបស់ខ្ញុំ ។

ប៊ុនថន៖	ចឹងដីចម្ការអីមីងមានចាប់បានអីទេ?

ពោះ៖	ចាប់បានខ្លះដែរ ដីស្រែដីចំការ ។

ប៊ុនថន៖	កាលហ្នឹងគេចាប់ដីរបៀបយ៉ាងម៉េចទៅមីង?

ពោះ៖	យើងហ៊ានកាប់ព្រៃបានទៅ យើងហ៊ានកាប់ព្រៃមីន ព្រៃអីហ្នឹង ។

ប៊ុនថន៖	ចឹងអត់មានកំណត់ទេកាប់បានប៉ុន្មានយកប៉ុណ្ណឹងទៅ?

ពោះ៖	អត់មានកំណត់ទេ កាប់បានប៉ុន្មានយកប៉ុណ្ណឹងទៅ គេអ្នកហ៊ានកាប់បានទៅ អ្នកមិនហ៊ាន អត់ដីដែលហ្នឹង នៅនេះខ្លះអត់មានដីច្រើនណាស់ ។

ប៊ុនថន៖	អត់ដីចឹងធ្វើម៉េចទៅមីង?

ពោះ៖	អ្នកដីអត់ហ្នឹងណាស់ ដើរធ្វើការឲ្យគេ ស៊ីឈ្នួលគេទៅហ្នឹងឯង ។

ប៊ុនថន៖	មីងកាប់បានប៉ុន្មានរ៉ៃដែរ?

ពោះ៖	ខ្ញុំកាប់បានប្រហែលជា២០រ៉ៃជាងដែរ ហើយទិញគេបានខ្លះ ។

ប៊ុនថន៖	ចឹងទិញថែមទៀត?

ពោះ ចាស ។

ប៊ុនថន: ទាំងអស់ឥឡូវដាំចំការ?

ពោះ: ដាំដំឡូងខ្លួនឯង ។

ប៊ុនថន: បានផលទេមីង?

ពោះ: ដាំបានដែលហ្នឹង តែឥឡូវភ្លៀងជាប់ចឹងមិនដឹងជាយ៉ាងម៉េចហើយទេ មិនបានទៅមើលផងទឹកលិចអស់ខ្វះហើយដឹងសើច...។

ប៊ុនថន: ដាំតែចំការអត់មានធ្វើស្រែអីមីង?

ពោះ: ធ្វើស្រែដែលតែឆ្នាំនេះមិនបានធ្វើ អស់ទឹកទើបតែបានភ្លៀង ឆ្នាំនេះចោលស្រែ ។

ប៊ុនថន: ចឹងចង់សួរមីង មីងមកដល់ហ្នឹងពីមុនមកជីវភាពអ្នកភូមិគាត់ធ្វើអីដែលមីង?

ពោះ: មកពីដំបូងមកហ្នឹង ។

ប៊ុនថន: បាទ!ពីដំបូងមីងមកពីថៃអីហ្នឹង?

ពោះ: ពីដំបូងមក មកដល់ចាប់ដីអីរៀងខ្លួនហ្នឹង ហើយធ្វើស្រែធ្វើចំការហ្នឹង ។

ប៊ុនថន: តែរបបអី?

ពោះ: របបគេនៅបើកដែរ បើអង្គរបើក ។

ប៊ុនថន: ហ្នឹងបើកយ៉ាងម៉េចវិញ តាមចំនួនមនុស្សឬមួយយ៉ាងម៉េច?

ពោះ: តាមចំនួនមនុស្ស ។

ប៊ុនថន: តែហូបគ្រាន់ទេមីង?

ពោះ: ហូបគ្រាន់ ទើបឈប់បើកអង្ករឥឡូវហ្នឹង ។

ប៊ុនថន: ឈប់បើកឆ្នាំណាមីង?

ពោះ: ឈប់បើកយូរហើយមិនដឹងជាឆ្នាំណាទេ បើកអង្ករបានកាលកូនខ្ញុំនៅតូចៗនេះឯង ឥឡូវឈប់បើកយូរហើយ កាលមកពីថៃដំបូងហ្នឹងបើក ដល់ឥឡូវឈប់បើកយូរហើយ ឈប់បើកប្អូនដប់ឆ្នាំហើយដឹង ឈប់បើកយូរមែនទែនណាស់ ឈប់បើកតាំងពីកូននៅតូចម្ល៉េះ ។

ប៊ុនថន: បាទ ។

ពោះ: ឈប់បើកតាំងពីយើងនៅនេះ តាំងពីយើងផ្តាច់ខ្លួនត្រូវគ្នានេះឯង ឈប់បើកនេះឯង ។

ប៊ុនថន: ចឹងកាលពីមុនមកនៅបើក?

ពោះ: ចាស ។

ប៊ុនថន: ចឹងកាលយើងធ្វើស្រែចំការហ្នឹង?

ពៅៈ ឈប់បើកតាំងពីយើងធ្វើស្រែចំការបានខ្លួនយើងឈប់បើកតែម្តង ផ្តាច់ខ្លួនហើយហ្នឹងឈប់បើកហ្នឹង ឈប់បើកអង្ករឈប់បើកខោអាវ ឈប់បើកអី រកហូបខ្លួនយើងឯកជនទៅ បើគេអ្នកនៅធ្វើទាហានឥឡូវគេនៅតែបើកចិន បើកអង្ករបើកលុយអីបើយើងឈប់អត់បានបើកទេ ។

ប៊ុនថន: ចឹងមីងនិយាយថាអ្នកអត់បានដីហ្នឹងពេលឈប់បើកធ្វើម៉េចទៅមីង?

ពៅៈ ចេះតែដើររកខ្លួនឯងទៅ ស៊ីឈ្នួលគេទៅអ្នកអត់មានដីហ្នឹង ទៅធ្វើការឲ្យខ្មែរទៅធ្វើការឲ្យថៃចឹងទៅ ។

ប៊ុនថន: មីងចង់សួរមីងមួយ កាលមុនសមាហរណកម្មហើយក្រោយមកដូចថាជីវភាពរឿលំបាកគិតថាលំបាកឬមួយខុសប្លែកពីមុនឬមួយក៏ស្រួលជាងមុនយ៉ាងម៉េចដែលមីង?

ពៅៈ ពីមុនហ្នឹងឥឡូវ ឥឡូវនេះស្រួលជាងហ្នឹងហើយ ពីមុនលំបាកហ្នឹងឯងយើងនៅរួមឯងជនពិបាកហ្នឹងឯងនៅរួម ឥឡូវយើងឯងជនស្រួលហើយ យើងរកបានខ្លួនយើងហូបខ្លួនយើងទៅ ។

ប៊ុនថន: ចឹងអ្នកអត់?

ពៅៈ អ្នកអត់ប្រឹងប្រែងរកខ្លួនយើងទៅ ឥឡូវមានពីណាចែកដីឲ្យយើងអត់ៗទៅ ។

ប៊ុនថន: បាទ ។

ពៅៈ ទាល់តែយើងមានលុយកាក់ទិញគេខ្វះ ។

ប៊ុនថន: ចឹងកាលសម័យតស៊ូមីងធ្លាប់ជួបអ្នកលំបាកមីងធ្លាប់ឃើញទេ មីងជួយអីទេ កាលមីងនៅតស៊ូ?

ពៅៈ ពិបាករស់នៅហ្នឹង ។

ប៊ុនថន: បាទ!ដូចជាមីងធ្លាប់ឃើញគេពិបាក មីងធ្លាប់ជួយជាម្ហូបអាហារអីទេ?

ពៅៈ អត់ដែលបានជួយទេកាលហ្នឹង បើយើងហូបបាយរួមនោះមានអីជួយ ។

ប៊ុនថន: បាទ ។

ពៅៈ ហ្នឹងឯងតាមកន្លែងហូបបាយរួមមានអីជួយហ្នឹងហើយតាមកន្លែងហូបបាយរួម ។

ប៊ុនថន: មីងនៅតែធ្វើការមានដើរណា?

ពៅៈ ចាស!នៅតែកន្លែងមានដើរអី យើងនៅតែកន្លែងធ្វើការរៀងៗខ្លួនចឹងទៅ ។

ប៊ុនថន: ចឹងមីងរាល់ថ្ងៃរកស៊ីអីដែរមីង?

ពៅៈ មីងធ្វើស្រែធ្វើចំការ ។

ប៊ុនថន: មានរកស៊ីអីផ្សេងទៀតទេ?

ពៅៈ អត់ទេ សើច...។

ប៊ុនថនៈ ចឹងពូ?

ពៅៈ ពូមុនគាត់ធ្វើទាហានឥឡូវឈប់ហើយ អត្រែតហើយធ្វើស្រែធ្វើចំការ ។

ប៊ុនថនៈ ចឹងទិញឡាននេះគាត់រត់?

ពៅៈ ឡានទិញមកមិនដែលរត់ឈ្នួលប៉ុន្មានដងហ្នឹង សើច...។

ប៊ុនថនៈ ម៉េចចឹងមីង?

ពៅៈ វាអត់មានម៉ូយហើយផ្លូវវាលំបាក កូនវាមិនសូវទៅនេះ ។

ប៊ុនថនៈ ចឹងកូនអ្នកបើក?

ពៅៈ ចាស ។

ប៊ុនថនៈ មិនមែនពូទេ?

ពៅៈ កូនយូរៗបានទៅម្ដង ។

ប៊ុនថនៈ ចឹងមានគ្រួសារហើយនៅ?

ពៅៈ នៅ មានអាបងនោះហើយដើរទៅមិញនោះ ។

ប៊ុនថនៈ ចឹងមិញមីងថាកូនមានប៉ុន្មាននាក់?

ពៅៈ កូនបី ។

ប៊ុនថនៈ កូនបីនាក់?

ពៅៈ ចាស ។

ប៊ុនថនៈ ប្រុសពីរស្រីមួយ?

ពៅៈ ប្រុសទាំងអស់ហ្នឹង កូនបីសុទ្ធតែប្រុស ។

ប៊ុនថនៈ ចឹងបងកូនប្រសារ?

ពៅៈ កូនប្រសារ ។

ប៊ុនថនៈ ចឹងមីងរាល់ថ្ងៃហ្នឹងនៅជុំគ្នាជាមួយកូន?

ពៅៈ ជុំគ្នាជាមួយកូន ។

ប៊ុនថនៈ មីងនេះគេហៅភូមិអីវិញ?

ពៅៈ នេះភូមិថ្មី ។

ប៊ុនថនៈ ភូមិថ្មី ឃុំម៉ាឡៃ?

ពៅៈ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

ប៊ុនថន៖	ចឹងមីងប្រវត្តិមីងពីដំបូងមក មីងមានចាំកន្លែងណាជាងគេទេមីង មីងចាប់អារម្មណ៍ដូចថា ស្រួលឬមួយលំបាកអី មីងមានចាំទេ ហើយចង់រៀបរាប់អី?

ពៅ៖	ខ្ញុំមិនសូវចាំទេសើច...។

ប៊ុនថន៖	ដូចថាអនុស្សាវរីយ៍អីចឹង?

ពៅ៖	កាលហ្នឹងមីងនៅកន្លែងអត់សូវមានយ៉ាប់អីប៉ុន្មានផង បើយើងនៅតែកន្លែងមន្ទីរហ្នឹង ណាស់។

ប៊ុនថន៖	បាទ។

ពៅ៖	មិនសូវមានកន្លែងពិបាក។

ប៊ុនថន៖	ចឹងកាលមីងចាកចេញពីស្រុកឆ្នាំណា?

ពៅ៖	ឆ្នាំ៧៦។

ប៊ុនថន៖	កាលមីងចាកចេញមកមីងមានដឹងដំណឹងពីឪពុកម្តាយអីទេ មានដែលទទួលដំណឹងពីគាត់វិញ ទេមីង?

ពៅ៖	អត់ចេញមករហូតមិនដែលបានទទួលដំណឹងអីទេ មិនដែលបានជួបទេ ទាល់តែយើងទៅ ស្រុកវិញហ្នឹងឯង អ្នកស្រុកគេថាស្លាប់អស់ហើយហ្នឹងណាស់។

ប៊ុនថន៖	ចឹងមីងចេញមកមាននឹកផ្ទះនឹកបងប្អូនអីទេ?

ពៅ៖	កាលយើងចេញដំបូងនឹកដែរ ដល់បែកយូររាល់ឆ្នាំទៅចេះតែរំសាយទៅ។

ប៊ុនថន៖	មីងទៅលេងផ្ទះកាលឆ្នាំណាមីង កាលទៅលេងផ្ទះទៅលេងស្រុកវិញណាស់?

ពៅ៖	ទៅកាលយើងផ្តាច់ខ្លួនហើយនេះ។

ប៊ុនថន៖	ឆ្នាំ៩០ជាង?

ពៅ៖	ចាស។

ប៊ុនថន៖	ឧស្សាហ៍បានទៅលេងទេ?

ពៅ៖	កាលដំបូងបានទៅម្តង ឥឡូវឧស្សាហ៍បានទៅដែរ ទៅបានញឹកញាប់ដែលដល់យើងស្រួល ចេះ។

ប៊ុនថន៖	តាំងពីមុនមកបានទៅប៉ុន្មានដងហើយមីង?

ពៅ៖	បានទៅបីទៅបួនដងហើយ។

ប៊ុនថន៖	ទៅដល់ដំបូងអ្នកផ្ទះបងប្អូននិងអ្នកភូមិមីងស្គាល់ទេ?

ពៅ៖	ស្គាល់។

ប៊ុនថន៖	ចំណាំមីងទេ?

ពោះ: ចំណាំបានទាំងអស់ហ្នឹង ។

ប៊ុនថន: ចឹងបងប្អូននៅរស់ទាំងអស់ឬមួយយ៉ាងម៉េចដែរ?

ពោះ: ស្លាប់អស់ពីរនាក់ហើយ បីនាក់ហើយបងប្អូន ។

ប៊ុនថន: ស្លាប់ពេលណាទៅមីង?

ពោះ: ទើបស្លាប់ឥឡូវៗនេះដែលហ្នឹងណាស់ ប៉ុន្មានឆ្នាំហើយ ។

ប៊ុនថន: និយាយថាពីមុនគាត់នៅ?

ពោះ: ចាសៗ!គាត់នៅស្រុកភូមិ ។

ប៊ុនថន: អត់មានបាត់បង់ទេ?

ពោះ: អត់ទេ ។

ប៊ុនថន: ចឹងអ្នកភូមិអីមានមកលេងមីងទេ មីងខានទៅយូរចឹង?

ពោះ: មកលេងសើច...មកសួរសុខទុក្ខ ។

ប៊ុនថន: ចឹងកាលទៅលេងដំបូង គេថាមីងស្លាប់ចឹងមីងមានអារម្មណ៍យ៉ាងម៉េចដែលមីង?

ពោះ: ជួបគ្នាហ្នឹងចាស់ៗយំរំពងទ្រហ៊ឹង ។

ប៊ុនថន: មីងជួបដំបូងមីងមានអារម្មណ៍យ៉ាងម៉េចដែរ?

ពោះ: ទៅដំបូងអរផងភ័យផង ។

ប៊ុនថន: ភ័យយ៉ាងម៉េចវិញទៅ?

ពោះ: ភ័យយើងបែកពីម៉ែឪបងប្អូនយូរទៅ ទៅដល់ម៉ែឪអស់ទៀត គាត់ស្លាប់អស់ទៀតនៅតែបងប្អូន ។

ប៊ុនថន: ចឹងឥឡូវបងប្អូនមានដែលមកលេងអីទេ?

ពោះ: មកដែល មកបានពីរបីដងដែរ ។

ប៊ុនថន: បែកយូរចឹងមីងចំណាំភូមិឃុំដែលកាលទៅ?

ពោះ: ចំណាំបានកាលហ្នឹង ។

ប៊ុនថន: ទៅកាលហ្នឹងដើរសួរគេឬមួយទៅឃើញតែម្តង?

ពោះ: យើងទៅដល់យើងទៅតែភូមិយើងទៅសួរគេទៅបងប្អូននៅរស់ប៉ុន្មានអីប៉ុន្មានគេប្រាប់ហើយ ។

ប៊ុនថន: ចឹងបានទៅបីដងហើយមីង?

ពោះ: ចាស!បានទៅបីដងបួនដងដែរ តែទៅកាលបងគាត់ស្លាប់អីផង ។

ប៊ុនថន: ប្លែកទេមីងកាលទៅមានប្លែកទេភូមិឃុំ?

ពោះ៖ ទៅឥឡូវបងប្អូនចេញពីស្រុកអស់ហើយ អត់នៅក្នុងភូមិចាស់ទេ មកនៅកំពង់សោមអស់ហើយ ។

ប៊ុនថនៈ ទាំងអស់តែម្ដងមីង?

ពោះ៖ ចាស!បងប្អូនបង្កើតមកនៅហ្នឹងអស់ហើយ នៅស្រុកតែមីងមាទេ ។

ប៊ុនថនៈ ចឹងមីងខ្ញុំដូចជាអស់ហើយ មីងមានអីចង់បន្ថែមទៀតទេ?

ពោះ៖ អត់មានអីទេអូនសើច... ។

ប៊ុនថនៈ ចឹងខ្ញុំដូចជាអស់អីសួរមីងដែរ ។

ពោះ៖ ចាស ។

**«ចប់»**